# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ០៩១ សណា១៧ អអក

ភ្នំពេញ, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧

## សេចក្ដីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្ដីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី ខៀវ សុខា សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃក្រុងសិរីសោភ័ណ្ឌ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ និងស្រុកបវេល ស្រុកថ្មគោល ខេត្តបាត់ដំបង

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងក្រុងសិរីសោភ័ណ្ឌ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ និងស្រុកបវេល ស្រុកថ្មគោល ខេត្តបាត់ដំបង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណលេខ ៣២៤ អ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ ឲ្យលោកស្រី ខៀវ សុខា សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃក្រុងសិរីសោភ័ណ្ឌ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ និងស្រុកបវេល ស្រុកថ្មគោល ខេត្តបាត់ដំបង ក្នុងអាណត្តិមុនគឺ ១០ឆ្នាំ ។ ដើម្បីជួយសម្រួលអ្នកកាន់អាជ្ញាបណ្ណក្នុងការខ្ចីទុនពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងពីប្រភពហិរញ្ញវត្ថុនានា សម្រាប់ការពង្រីកការផ្គត់ផ្គង់អគ្គិសនីទៅកាន់តំបន់ដែលពុំមានអគ្គិសនីប្រើប្រាស់នៅក្នុងតំបន់អាជ្ញាបណ្ណរបស់ខ្លួន និងយោងតាមការវាយតម្លៃលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណលោកស្រី ខៀវ សុខា ដោយបន្ថែមអាណត្តិអាជ្ញាបណ្ណពី ១០(ដប់)ឆ្នាំ ទៅ ១២(ដប់ពីរ)ឆ្នាំ ដូចមានខ្លឹមសារជូនភ្ជាប់ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្ដល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា លើខ្លឹមសារនៃសេចក្ដីព្រាងសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្ដីព្រាងសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ .................... ..............................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងក្រុងសិរីសោភ័ណ្ឌ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ និងស្រុកបវេល ស្រុកថ្មគោល ខេត្តបាត់ដំបង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬ ផ្ដល់យោបល់លើខ្លឹមសារនៃការចេញសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី ខៀវ សុខា អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្ដល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៦ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា **"អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ"** ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**បណ្ឌិត.ធី នរិន្ទ**

**សេចក្តីព្រាង**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

**ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា**

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

# សេចក្តីសម្រេចកែសម្រួលលើកទី៣
# លើឯកសារអាជ្ញាបណ្ណលេខ ៣២៤ ឯអ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ សម្រាប់លោកស្រី ខៀវ សុខា ធ្វើសេវាកម្មអគ្គិសនីនៅ ផ្នែកខ្លះនៃក្រុងសិរីសោភ័ណ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ និងស្រុកបវេល ស្រុកថ្មគោល ខេត្តបាត់ដំបង

**សម្រាប់ការបន្ថែមអាណត្តិអាជ្ញាបណ្ណ**

**(ក្នុងគោលបំណងជួយសម្រួលការខ្ចីឥណទានពីមូលនិធិអគ្គិសនីភាវូបនីយកម្ម ជនបទ "ម.អ.ជ" ដើម្បីពង្រីកបណ្តាញទៅតំបន់ពុំទាន់មានអគ្គិសនី)**

# DECISION ON THE THIRD REVISION

OF THE LICENSE DOCUMENT No. 324 LD DATED SEPTEMBER 13, 2011 FOR MRS. KHIEV SOKHA FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF KRONG SEREYSOPHORN, MONGKULBOREY DISTRICT, BANTEAY MEANCHEY PROVINCE, AND BAVEL, THMARKOL DISTRICTS, BATTAMBANG PROVINCE

**FOR EXTENDING THE TERM OF LICENSE**

**(To facilitate to get the funds from Rural Electrification Fund "REF" for extending the electric supply to non-electrified areas)**

ថ្ងៃទី ខែ ឆ្នាំ២០១៧

..... ....., 2017